សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨១០
ចុះថ្ងៃទី ២២-០៨-២០១២
សាលដីកា
លេខ ៖ ៦១ "ក្រ.III.ស"
ចុះថ្ងៃទី ០៦-០៨-២០១៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៨១០ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១២ ដែលមាន:

១- ជនជាប់ចោទឈ្មោះ [redacted] សេង ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាមិញ ឃុំក្រយារ ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃភូមិ[redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ៤នាក់ ទោសពីមុនគ្មាន ឃុំខ្លួនលេខ ៥១៩ តព្រ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១។

២- ជនជាប់ចោទឈ្មោះ [redacted] ថា ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ[redacted] ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មុខរបរក្រុមប្រឹក្សាស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ៣នាក់ ទោសពីមុនគ្មាន ឃុំខ្លួនលេខ ៥២០ តព្រ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១។

មានលោក [redacted] វិបុល ជាមេធាវីការពារ។

<u>ជាប់ចោទពីបទ:</u> ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅភោជនីយដ្ឋានសេលីប ផ្លូវលេខ ៨១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ប្រធាន

## ៦ដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ១៥ និង០៥នាទី សមត្ថកិច្ចប្រឆាំងគ្រឿងញៀន បានចុះធ្វើការបង្ក្រាបជាក់ស្តែងករណីជួញដូរគ្រឿងញៀនខុសច្បាប់ នៅចំណុចភោជនីដ្ឋានសេលីប រួចធ្វើការឃាត់ខ្លួនជនត្រូវចោទចំនួន ៣នាក់ មានឈ្មោះ [redacted] សេង, [redacted] ស៊ាងហ៊ាប និងឈ្មោះ [redacted] ថា រួមជាមួយវត្ថុតាងមាន ថ្នាំញៀនម្សៅប្រភេទមេតំហ្វេតាមីន (ទឹកកក) ទម្ងន់ ៣៩,៦ក្រាម ទូរស័ព្ទដៃម៉ាកណូគាចំនួន ៣គ្រឿង និងនាឡិកាដៃចំនួន ១គ្រឿង។

ក្រោយពីធ្វើការសាកសួរទើបដឹងថា ឈ្មោះ [redacted] ថា ជាអ្នករកម៉ូយនៅភ្នំពេញ មានមនុស្សស្រីត្រូវការរកទិញគ្រឿងញៀនប្រហែលកន្លះខាំឱ្យឈ្មោះ [redacted] ស៊ាងហ៊ាប ហៅ រិទ្ធ បន្ទាប់មកឈ្មោះ [redacted] ស៊ាងហ៊ាប បានឱ្យឈ្មោះ [redacted] សេង យកគ្រឿងញៀនដែលពួកខ្លួនទិញពីឈ្មោះ [redacted] រស្មី ហៅ មី៉ នៅខេត្តស្ទឹងត្រែង ដោយប្រាប់ថា មានម៉ូយរកទិញគ្រឿងញៀនកន្លះខាំតម្លៃ ២៥០០ដុល្លារ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសលើឈ្មោះដូចខាងក្រោម:

- ឈ្មោះ[redacted] សេង ភេទប្រុស អាយុ ៤២ឆ្នាំ។
- ឈ្មោះ[redacted] ស៊ាងហ៊ាប ហៅ[redacted]សារិទ្ធ ភេទប្រុស អាយុ ៣១ឆ្នាំ។
- ឈ្មោះ[redacted]ថា ភេទប្រុស អាយុ ៤៣ឆ្នាំ

គឺដាក់ពន្ធនាគារម្នាក់ៗកំណត់ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ម្នាក់ៗកំណត់ ១០.០០០.០០០រៀល (ដប់លានរៀល) ដាក់ចូលថវិការដ្ឋ។

ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចភោជនីយដ្ឋានសេលីប ផ្លូវលេខ ៨៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់វិសោធនកម្ម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់។

២- ផ្តន្ទាទោសលើឈ្មោះ[redacted] រស្មី ហៅ មី៉ ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ និងពិន័យចំនួន ១០.០០០.០០០រៀល (ដប់លានរៀល) ដាក់ជាថវិការដ្ឋ ដោយបង្គាប់ឱ្យអាណាព្យាបាលបង់ប្រាក់ពិន័យ។

ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចភោជនីយដ្ឋានសេលីប ផ្លូវលេខ ៨៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់វិសោធនកម្ម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់ និងតាមមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ។

៣- វត្ថុចាប់យក: ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២១ វត ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរ ដូចខាងក្រោម:

ក- ស្រោមសំបុត្រពណ៌គគីរបិទជិតមានចុះហត្ថលេខាសមត្ថកិច្ច និងស្នាមផ្តិតមេដៃជនសង្ស័យ នៅលើកញ្ចប់មានសរសេរថា កញ្ចប់វត្ថុតាងថ្នាំញៀនម្សៅទឹកកក ទម្ងន់ ៣៩,៦ក្រាម ត្រូវរឹបអូសបំផ្លាញចោល តាមមាត្រា ៨៥ នៃច្បាប់វិសោធនកម្ម ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ- ស្រោមសំបុត្រពណ៌គគីរបិទជិតដែលមានសរសេរថា សម្ភារៈវត្ថុតាងដកហូត ទូរស័ព្ទម៉ាក Nokia ៧១០០ មួយគ្រឿង, ទូរស័ព្ទម៉ាក Nokia ១២០៨ មួយគ្រឿង, ទូរស័ព្ទម៉ាក Nokia ៦៦១០ មួយគ្រឿង និង នាឡិកាដៃម៉ាក Longine មួយគ្រឿង ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។ តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៤- សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted]សេង ឈ្មោះ [redacted] ស៊ាងហ៊ាប ឈ្មោះ [redacted]ថា និងកំបាំងមុខឈ្មោះ [redacted]រស្មី ហៅ មី៉ និង ប្រកាសជាសាធារណៈនាថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]សេង ឈ្មោះ [redacted] ស៊ាងហ៊ាប ឈ្មោះ [redacted]ថា និងកំបាំងមុខឈ្មោះ [redacted] រស្មី ហៅ មី៉។

ទុកសិទ្ធិប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១១ របស់ឈ្មោះ [redacted]សេង ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ របស់ សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។
- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១១ របស់ឈ្មោះ [redacted]ថា ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ របស់ សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។
- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។
- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted]សេង ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មិនសុខចិត្តដើម្បីឲ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោស ខ្លួនពិតជាបានប្រព្រឹត្តដូចអង្គហេតុមែន។ ឈ្មោះ រស្មី ខ្លួនអត់ស្គាល់ទេ ឈ្មោះ មី ជាអ្នកនាំយកថ្នាំឲ្យឈ្មោះ[redacted]ស៊ីមហៀប ហើយគាត់យកមកឲ្យខ្លួន ខ្លួនអត់ដឹងថា ជាថ្នាំញៀនទេ គេប្រាប់ខ្លួនថា ជាថ្នាំសប្បាយ ឈ្មោះ [redacted] ថា គាត់ស្គាល់ថៅកែ។ ខ្លួនធ្លាប់តែម្តងនេះ ខ្លួនមិនទាន់បានទទួលសោហ៊ុយទេ គេសន្យាឲ្យខ្លួន ២០០ដុល្លារ ខ្លួនទៅស្ទឹងត្រែងទៅទទួលថ្នាំយកមកភ្នំពេញ។ ខ្លួនមានមុខរបរធ្វើចម្ការ កូនខ្លួនតូចៗ ខ្លួនអត់ចេះអក្សរទេ ប្រពន្ធខ្លួនអត់មកទេ បើខ្លួនចេញទៅខ្លួនឈប់ប្រព្រឹត្តហើយ។ សំណូមពរ សុំបន្ធូរបន្ថយទោស។

### សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] សេង និងពាក្យសុំដកបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ[redacted]ថា បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ សាលាឧទ្ធរណ៍ទទួលយកមកជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ជនជាប់ចោទឈ្មោះ [redacted] ថា បានសុំដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដូច្នេះ សូមសភាព្រហ្មទណ្ឌ ចំណាយចេញពីបញ្ជី។ ដោយឡែកបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted]សេង គួរត្រូវបានបដិសេធ ចោល និងសូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ របស់សាលា ដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

កូនក្តីខ្លួនប្តឹងឧទ្ធរណ៍ ដោយសារគាត់ចង់បានស្ថានសម្រាល គាត់បានសារភាពនូវទោសកំហុសហើយ បើពិនិត្យទោសតាមមាត្រា ៣៣ ថ្មី គឺកម្រិតនៃការផ្តន្ទាទោសអប្បរមាហើយ ដោយគាត់មិនមានចំណេះដឹង ក្រីក្រមិនបានរៀនសូត្រ គាត់មិនដឹងថា ជាថ្នាំញៀនទេ គាត់ដឹងតែថា ជាថ្នាំសប្បាយ ដោយគាត់មានកូនរហូតដល់ ៥នាក់ តូចៗ សុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោស តាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១១ របស់ឈ្មោះ [redacted]សេង ជាជនជាប់ចោទធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមពាក្យសុំដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ជនជាប់ចោទឈ្មោះ[redacted]ថា បានសុំដកបណ្តឹងឧទ្ធរណ៍លេខ ៦៧៤ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១១ របស់ខ្លួនវិញ ដោយព្រមទទួលអនុវត្តតាមសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ (ឃ) ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដូច្នេះ សាលាឧទ្ធរណ៍មិនពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទរូបនេះទេ។

៣- តាមចម្លើយជនជាប់ចោទថា នៅក្នុងឆ្នាំ២០១១ ខ្លួន និងឈ្មោះ[redacted] ស៊ាងហ៊ាប បានបបួលគ្នារកស៊ីថ្នាំញៀន ហើយក៏បានទៅខេត្តស្ទឹងត្រែងដើម្បីទិញថ្នាំញៀនពីឈ្មោះ ម៉ី [redacted]រស្មី)។ ថ្នាំញៀននេះក្នុងមួយកញ្ចប់តម្លៃ ២.៥០០ដុល្លារអាមេរិក ហើយខ្លួនយកទៅលក់តម្លៃ ៣.០០០ដុល្លារអាមេរិក, គេឲ្យតម្លៃជើងសារពួកខ្លួនក្នុងម្នាក់ៗចំនួន ២០០ដុល្លារអាមេរិក ក្រោយពីទិញបានខ្លួនបានយកថ្នាំញៀនទៅទុកនៅផ្ទះខ្លួន នៅឯខេត្តព្រះវិហារ។ លុះដល់ថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១១ ឈ្មោះ[redacted] ស៊ាងហ៊ាប ប្រាប់ខ្លួនថា ខ្លួនគេរកម៉ូយទិញថ្នាំញៀនបានហើយ ទើបខ្លួនយកថ្នាំញៀនមកភ្នំពេញ ដើម្បីលក់ឲ្យម៉ូយ។

៤- មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទ ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចភោជនីយដ្ឋានសេលីប ផ្លូវលេខ ៨៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ចំពោះឈ្មោះ [redacted] សេង ឯចំពោះជនជាប់ចោទឈ្មោះ[redacted]ថា គួរចំណាយរឿងចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សេង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- ក- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ២ ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ចំពោះជនជាប់ចោទឈ្មោះ [redacted] សេង។

ខ- ចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ ៨១០ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ចេញពីបញ្ជីជំនុំជម្រះសាលាឧទ្ធរណ៍ ចំពោះតែជនជាប់ចោទឈ្មោះ [redacted]។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សេង និងមេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០១៣
**ក្រឡាបញ្ជី**